ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអភិវឌ្ឍន៍ជនបទ

លេខ: ១០០/១៤ ក.អ.ជ

ថ្ងៃចន្ទ ៧រោច ខែស្រាពណ៍ ឆ្នាំមមី ព.ស. ២៥៥៨

រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែសីហា គ.ស. ២០១៤

# សេចក្តីណែនាំ

## ស្តីពី

## ការរៀបចំរបាំងសុវត្ថិភាពនៅតាមទីតាំងផ្លូវជនបទដែលខូចខាត ដោយសារគ្រោះទឹកជំនន់ឆ្នាំ ២០១៤

គ្រោះទឹកជំនន់នៅខែកក្កដា និងសីហា ឆ្នាំ ២០១៤ នេះ បានបង្កឲ្យមានការខូចខាតយ៉ាងធ្ងន់ធ្ងរដល់ហេដ្ឋារចនាសម្ព័ន្ធជនបទជាច្រើនកន្លែងនៅតាមបណ្តាខេត្តមួយចំនួន នៃព្រះរាជាណាចក្រកម្ពុជា។

ដើម្បីធានាបាននូវសុវត្ថិភាពដល់អ្នកធ្វើដំណើរគ្រប់រូបនៅលើផ្លូវជនបទ ក្រសួងអភិវឌ្ឍន៍ជនបទសូមធ្វើការណែនាំដល់មន្ទីរអភិវឌ្ឍន៍ជនបទ ដែលបានរងការប៉ះពាល់ដោយសារគ្រោះទឹកជំនន់ទាំងអស់ដូចខាងក្រោម÷

1. ខិតខំសម្របសម្រួល និងសហការជាមួយអាជ្ញាធររាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីចុះពិនិត្យ និងកំណត់ទីតាំងតាមកំណាត់ផ្លូវជនបទ និងសំណង់សិល្បការដទៃទៀតដែលទឹកហូរច្រោះដាច់និងបាក់ស្រុត ដើម្បីរៀបចំដាក់ស្លាកសញ្ញាប្រយ័ត្នគ្រោះថ្នាក់ និងដាក់របាំងសុវត្ថិភាព។
2. ខិតខំសម្របសម្រួល និងសហការជាមួយអាជ្ញាធររាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ដើម្បីចាត់វិធានការជាក់ស្តែងនិងបន្ទាន់ ដើម្បីថែរក្សាបណ្តាញផ្លូវជនបទគ្រប់ប្រភេទដែលបានរងការប៉ះពាល់ដោយគ្រោះទឹកជំនន់ ដោយដាក់បម្រាមហាមឃាត់រថយន្ត និងមធ្យោបាយដឹកជញ្ជូនធុនធ្ងន់ឆ្លងកាត់លើផ្លូវដែលទើបតែរងគ្រោះដោយសារទឹកជំនន់កុំឲ្យកាន់តែខូចខាតធ្ងន់ធ្ងរបន្ថែមទៀត។
3. រៀបចំផែនការជួសជុលបន្ទាន់នៅពេលដែលស្ថានភាពអំណោយផល។

ទទួលបានសេចក្តីណែនាំនេះ សូមលោក លោកស្រីប្រធានមន្ទីរអភិវឌ្ឍន៍ជនបទរាជធានី ខេត្ត ត្រូវយកចិត្តទុកដាក់អនុវត្តឲ្យបានទាន់ពេលវេលា និងទទួលបានជោគជ័យ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រដ្ឋមន្ត្រី

ជា សុផារ៉ា

**ចម្លងជូន**÷

- សាលារាជធានី ខេត្ត
- ឯកសារ